**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
ROYAUME DU CAMBODGE
Nation Religion Roi

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
MINISTERE DE L'ECONOMIE ET DES FINANCES

លេខៈ ៥៨០ សហវ.ប្រក.

រាជធានី ភ្នំពេញ ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ ២០០២

# ប្រកាស

## ស្តីពី

## ការកែសម្រួលគណនីក្នុងប្លង់គណនេយ្យសាធារណៈ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ០២ នស/រកម/៩៤ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ។
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦ /១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។
- បានឃើញព្រះរាជក្រមលេខ ០១ នស/រកម/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០១/១៥ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០២ ។
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ/បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ/បក ចុះថ្ងៃ ទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ ។
- បានឃើញប្រកាសលេខ ០០៩ ប្រក.សហវ ចុះថ្ងៃ ទី ២២ ខែ មករា ឆ្នាំ ១៩៩៤ ស្តីពីប្រព័ន្ធគណនីរបស់រតនាគារជាតិ ។
- តាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## សំរេច

**ប្រការ១:** ត្រូវបានកែសំរួលគណនីលេខ **540** (ប្រាក់បញ្ញើជារូបិយបណ្ណ័ដែលអាចប្រើប្រាស់បានភ្លាមៗ) នៅក្នុងប្រពន្ធ័គណនីនៃគណនេយ្យរដ្ឋ ដោយបំបែកទៅជាអនុគណនីមួយចំនួនស្របតាមគណនីទាំងឡាយដែលកំពុងគ្រប់គ្រងដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលមានឈ្មោះ និង លេខសំគាល់ដូចខាងក្រោម:

១- អនុគណនីលេខ 540.01 ឆ្លុះបញ្ចាំងទៅនឹងគណនីប្រាក់បញ្ញើឯកជនភាវូបនីយកម្ម ដែលមានលេខ 0102-35-1211-T020 នៅធនាគារជាតិនៃកម្ពុជា ។

២- អនុគណនីលេខ 540.02 ឆ្លុះបញ្ចាំងទៅនឹងគណនីប្រាក់បញ្ញើថវិកាចរន្ត ដែលមានលេខ 0102-35-1211-T023 នៅធនាគារជាតិនៃកម្ពុជា ។

៣- អនុគណនីលេខ 540.03 ឆ្លុះបញ្ចាំងទៅនឹងគណនីប្រាក់បញ្ញើសំរាប់ការទូទាត់បំណុលជំនួយជប៉ុនទី 1 ដែលមានលេខ 0102-35-1211-T026 នៅធនាគារជាតិនៃកម្ពុជា ។

៤- អនុគណនីលេខ 540.04 ឆ្លុះបញ្ចាំងទៅនឹងគណនីប្រាក់បញ្ញើជំនួយជប៉ុនទី 2 ដែលមានលេខ 0102-35-1211-T033 នៅធនាគារជាតិនៃកម្ពុជា ។

៥- អនុគណនីលេខ 540.05 ឆ្លុះបញ្ចាំងទៅនឹងគណនីប្រាក់បញ្ញើពិសេស សំរាប់កម្មវិធីអភិវឌ្ឍន៏កសិកម្ម (ADB) ដែលមានលេខ0102-35-1211-T040នៅធនាគារជាតិនៃកម្ពុជា ។

៦- អនុគណនីលេខ 540.06 ឆ្លុះបញ្ចាំងទៅនឹងគណនីប្រាក់បញ្ញើពីការដេញថ្លៃកូតា ដែលមានលេខ 0102-35-1211-T068 នៅធនាគារជាតិនៃកម្ពុជា ។

៧- អនុគណនីលេខ 540.07 ឆ្លុះបញ្ចាំងទៅនឹងគណនីប្រាក់បញ្ញើឥណទាន សំរាប់កែតំរូវរចនាសម្ពន្ធ័ (S A C) ដែលមានលេខ 0102-35-1211-T082 នៅធនាគារជាតិនៃកម្ពុជា ។

៨- អនុគណនីលេខ 540.08 ឆ្លុះបញ្ចាំងទៅនឹងគណនីប្រាក់បញ្ញើពិសេស សំរាប់កម្មវិធីអភិវឌ្ឍន៏ធនាគារជាតិដែលមានលេខ 0102-35-1211-T132 នៅធនាគារជាតិនៃកម្ពុជា ។

៩- អនុគណនីលេខ 540.09 ឆ្លុះបញ្ចាំងទៅនឹងគណនី ប្រាក់បញ្ញើពិសេស សំរាប់កម្មវិធីអភិវឌ្ឍន៏វិស័យអប់រំ ដែលមាន លេខ 0102-35-1211-T136 នៅធនាគារជាតិនៃកម្ពុជា ។

១០- អនុគណនីលេខ 540.10 ឆ្លុះបញ្ចាំងទៅនឹងគណនីប្រាក់បញ្ញើសំរាប់ការងារបុរេប្រទានសំរាប់ប្រជុំអាស៊ាន ( ASEAN ) ដែលមានលេខ 0102-35-1212-A023 នៅធនាគារជាតិនៃកម្ពុជា ។

១១- អនុគណនីលេខ 540.11 ឆ្លុះបញ្ចាំងទៅនឹងគណនីតាមដានចំនួនទឹកប្រាក់សំរាប់គំរោងការស្តារកំណាត់ផ្លូវជាតិលេខ 2 (តាកែវ - ភ្នំដិន) ដែលមានលេខ 01 02-35-1211-T142 នៅធនាគារជាតិនៃកម្ពុជា ។

១២- អនុគណនីលេខ 540.12 ឆ្លុះបញ្ចាំងទៅនឹងគណនីប្រាក់តំកល់ ដែលមានលេខ 01 02-35-1211-T140 នៅធនាគារជាតិនៃកម្ពុជា ។

**ប្រការ២:** គណនីលេខ ៥៤០ នេះ រតនាគារជាតិអាចបំបែកទៅជាអនុគណនីបន្ថែមទៀតក្រៅពីអនុគណនីទាំងឡាយ ដែលបានកំណត់ខាងលើទៅតាមតំរូវការជាក់ស្តែង ដែលទាក់ទងនឹងប្រភេទ ចរិកនៃប្រតិបត្តិការថ្មីៗទៀត ។

**ប្រការ៣:** កិច្ចបញ្ជីការនៅរតនាគារជាតិ ត្រូវផ្អែកទៅតាមសក្ខីបត្រ័ដើមដែលផ្ញើមកពីធនាគារជាតិនៃកម្ពុជា នាយកដ្ឋានពាក់ពន្ធ័ និង អង្គភាពគ្រប់គ្រងរូបិយបណ្ណ័បរទេស ។ នៅដំណាច់ខែនីមួយៗ រតនាគារជាតិត្រូវផ្ទៀងផ្ទាត់ជាមួយបញ្ជីវិភាគរបស់ធនាគារជាតិនៃកម្ពុជា ។

**ប្រការ៤:** អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ ប្រធានរតនាគារជាតិ និង អង្គភាពពាក់ពន្ធ័ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

**កន្លែងទទួល:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បី ជូនជ្រាប"
- ដូចប្រការ ៣ :
  "ដើម្បី អនុវត្ត"
- ឯកសារ-កាលប្បវត្តិ